F2

CEDAC

# កសិករ និង ធម្មជាតិ

# Farmer and Nature

កម្រងសៀវភៅសំរាប់អភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា

| លេខ ៤ ខែសីហា ឆ្នាំ ២០០៤ | Nº 4, August 2004 |
|---|---|

# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ



រៀបរៀងដោយៈ រាជ សុភាព

សេដាក, សីហា ២០០៤

**បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ**

**និពន្ធដោយ : រាជ សុភាព**

បោះពុម្ពលើកទី ១ នៅឆ្នាំ ២០០៤ ចំនួន ២០០០ ច្បាប់

បោះពុម្ពដោយ : រោងពុម្ពឥន្ទ្រីយ៍មាស

**© សេដាក / CEDAC 2004**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅស្តីអំពី " **បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ** " បានកើតឡើងជារូបរាងដោយឈរលើមូលដ្ឋាននៃការចុះសិក្សា និងបទពិសោធន៍ចិញ្ចឹមត្រីជាមួយកសិករកន្លងមកនៅខេត្តតាកែវ ព្រៃវែង និងស្វាយរៀង។ ខ្ញុំចងក្រងជាសៀវភៅនេះ ក្នុងគោលបំណងដើម្បីជួយបំភ្លឺបន្ថែមនូវបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារដល់កសិករមួយចំនួនដែលមិនទាន់ទទួលបច្ចេកទេសបានទូលំទូលាយ និងជួយផ្តល់យោបល់បន្ថែមដែលជាមូលដ្ឋានគ្រឹះក្នុងការចិញ្ចឹមត្រីរបស់ខ្លួនអោយបានទទួលផលខ្ពស់ជាងមុន។ ខ្ញុំព្យាយាមធ្វើយ៉ាងណាអោយសៀវភៅនេះមានលក្ខណៈសាមញ្ញ ដើម្បីអោយកសិករងាយយល់ និងអាចអនុវត្តបានក្នុងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ។

ខ្ញុំសូមថ្លែងអំណរគុណដល់កសិករដែលមានបទពិសោធន៍ចិញ្ចឹមត្រីកន្លងមកបានចូលរួមផ្តល់យោបល់ និងបទពិសោធន៍ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារដូចជា កសិករ ចាន់ សុធា កែវ សំអុល នាក់ ហ៊ីម ស ចាន់និត្ត កែវ ប៊ុនមិត្ត ថុល និង កាប៉ាក ( នៅខេត្តតាកែវ ) កសិករ អៀង យ៉ន ឃ្លោក ស៊ីម គង់ មឿង ចាន់ នឿន ( នៅខេត្តព្រៃវែង) និង កសិករ ទៀ សារ៉ុន រាជ ឆាន និង រាជ សុខា (នៅខេត្តស្វាយរៀង)។

ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់បុគ្គលិកសេដាកទាំងអស់ដែលបានចូលរួមចំណែកដូចជា លោក ម៉ា វាសនា យឹម សុខសុភាស់ ហួត ស៊ីណាត អ្នកស្រី ម៉ើ សុខជា កញ្ញា ម៉ុក ចិន្ដា ស៊ិន អង្គារសាធ និងសាស្ត្រាចារ្យមហាវិទ្យាល័យជលផលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងអ្នកឯកទេសវារីវប្បកម្មនៃនាយកដ្ឋានជលផល ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បណ្ឌិត យ៉ង សាំងកុមារ នាយកប្រតិបត្តិអង្គការសេដាក អ្នកស្រី ពាន សុខា អ្នកស្រី មាស និមល និង លោក យឹម សុផាណ្ណា ដែលបានចូលរួមចំណែកក្នុងការជួយនិពន្ធកែលំអ និង ជំរុញអោយសៀវភៅនេះចេញជារូបរាងឡើងសំរាប់កសិករ ។

យើងខ្ញុំក៏សូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការអុកស្វាមអាមេរិក (Oxfam America) ដែលបានឧបត្ថម្ភថវិកាក្នុងការផលិតសៀវភៅនេះ ។

ខ្ញុំយល់ថា សៀវភៅនេះមានចំនុចខ្វះខាតជាច្រើន ទាំងខ្លឹមសារ និងរូបភាព។ ខ្ញុំសប្បាយរីករាយនូវការជួយកែលំអពីសំណាក់អ្នកអាន និងអ្នកអនុវត្តផ្ទាល់ ឬ អ្នកមានចំណាប់អារម្មណ៍ផ្សេងៗ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុនចំពោះការចូលរួមចំណែកដ៏មានតំលៃនេះ។

**រាជ សុភាព**

អ្នកនិពន្ធ

# មាតិកាអត្ថបទ


សេចក្តីថ្លែងអំណរគុណ ទំព័រ

សេចក្តីផ្តើម ............ ១

១. ហេតុអ្វីបានជាយើងចិញ្ចឹមត្រី ? ............ ២

២. ចរិតរស់នៅនៃប្រភេទត្រីចិញ្ចឹមមួយចំនួន ............ ២

២.១.ប្រភេទត្រីក្រៅស្រុក ............ ២

២.២.ប្រភេទត្រីក្នុងស្រុក............ ៥

៣. ធនធាន និងកត្តាជាមូលដ្ឋានក្នុងការចិញ្ចឹមត្រី ............ ៧

៤. ប្រភពទឹក ............ ៨

៥. ការរៀបចំកន្លែងចិញ្ចឹមត្រី............ ៩

៥.១. ជ្រើសរើសទីតាំងជីកស្រះ ឬ ប្រឡាយ ............ ៩

៥.២. របៀបជីកស្រះ ឬ ប្រឡាយ............ ៩

៥.៣. របៀបរៀបចំប្រឡាយ ឬ ស្រះថ្មី............ ១១

៥.៤. របៀបរៀបចំប្រឡាយ ឬ ស្រះចាស់............ ១២

៦. ពេលវេលានៃការលែងកូនត្រីចិញ្ចឹម............ ១៣

៦.១. របៀបដឹកកូនត្រីពូជ............ ១៣

៦.២. របៀបលែងកូនត្រី............ ១៦

៦.៣. បរិមាណកូនត្រីដាក់ចិញ្ចឹម ............ ១៦

៧. ចំណីត្រី............ ១៧

៨. ចិញ្ចឹមត្រីក្នុងស្រែ ( ត្រី - ស្រូវ) ............ ២០

៩. ការគ្រប់គ្រង និងថែទាំត្រី............ ២២

១០. ការប្រមូលផលត្រី ............ ២៥

១១. ការពារ និងព្យាបាលជំងឺ............ ២៥

១២. បទពិសោធន៍សំខាន់ៗ របស់កសិករក្នុងការចិញ្ចឹមត្រី............ ២៦

១៣. ការសរុបនូវចំណុចសំខាន់ៗ និង សំណូមពរ ............ ២៩

ឧបសម្ព័ន្ធ

ឯកសារយោង

## បញ្ជីរូបភាព


រូបភាព ១ : ត្រីកាបស ........ ២
រូបភាព ២ : ត្រីកាបសាមញ្ញ ........ ៣
រូបភាព ៣ : ត្រីកាបឥណ្ឌា ........ ៤
រូបភាព ៤ : ត្រីឆ្ពិន ........ ៥
រូបភាព ៥ : ត្រីកន្ធរ ........ ៥
រូបភាព ៦ : ត្រីប្រា ........ ៦
រូបភាព ៧ : ធនធាន និងកត្តាជាមូលដ្ឋានក្នុងការចិញ្ចឹមត្រី ........ ៧
រូបភាព ៨ : របៀបពិនិត្យគុណភាពទឹកស្រះមុនដាក់ត្រីចិញ្ចឹម ........ ៨
រូបភាព ៩ : ពិនិត្យគុណភាពដី ដើម្បីជីកស្រះចិញ្ចឹមត្រី ........ ៩
រូបភាព ១០ : គំនូសកាត់ទទឹងស្រះ (មើលពីចំហៀងស្រះ) ........ ១០
រូបភាព ១១ : គំនូសកាត់ទទឹងប្រឡាយ (មើលពីចំហៀងប្រឡាយ) ........ ១១
រូបភាព ១២ : ដាក់ជីលាមកសត្វទ្រាប់បាតប្រឡាយ ........ ១២
រូបភាព ១៣ : បាចកំបោរស រួចហាលថ្ងៃបាតស្រះ ........ ១៣
រូបភាព ១៤ : បង្វឹកកូនត្រីពូជ មុនពេលកៀរដាក់ក្នុងហាប៉ា ........ ១៤
រូបភាព ១៥ : បន្សាំកូនត្រីក្នុងហាប៉ាមុនពេលដឹកជញ្ជូន (រយៈពេល ២៤ ម៉ោង) ........ ១៤
រូបភាព ១៦ : ដាក់កូនត្រីក្នុងថង់ប្លាស្ទិក កានដ័រ ប៉ោត ........ ១៥
រូបភាព ១៧ : របៀបលែងកូនត្រី ........ ១៦
រូបភាព ១៨ : វាស់ប្រវែងកូនត្រី ........ ១៧
រូបភាព ១៩ : ចិញ្ច្រាំបន្លែអោយត្រីស៊ី ........ ១៧
រូបភាព ២០ : ពិនិត្យចំណី និងបរិមាណត្រី ........ ១៨
រូបភាព ២១ : ស៊ុមដាក់ចំណីត្រី (ចកបាយទា ស្លែ ត្រកួន) ........ ១៩
រូបភាព ២២ : ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយភ្ជាប់ជាមួយស្រែ ........ ២០
រូបភាព ២៣ : ត្រីស៊ីរុក្ខជាតិ និង សត្វល្អិតក្នុងស្រែ (ត្រីស៊ីចំណីតាមស្រទាប់ផ្ទៃទឹក) ........ ២១
រូបភាព ២៤ : ស្រះចិញ្ចឹមត្រី ........ ២១
រូបភាព ២៥ : បន្ថែមទឹកចូលស្រះព្រោះដោយស្បៃមុងកុំអោយត្រីស្រែចូល ........ ២២
រូបភាព ២៦: សំអាតរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រី ........ ២៣
រូបភាព ២៧: ពពួកសត្វស៊ីកូនត្រី ........ ២៤
រូបភាព ២៨: ដាក់ចង្កៀងលើផ្ទៃស្រះទាក់ទាញសត្វល្អិត ........ ២៤
រូបភាព ២៩: ចងទន្រ្ទានខែត្រជាដុំដាក់ពន្លិចក្នុងទឹកស្រះចិញ្ចឹមត្រី (ជាចំណីត្រី) ........ ២៥


## បញ្ជីតារាង


តារាង ១ : ប្រភេទត្រីចិញ្ចឹមចំរុះ ........ ១៧
តារាង ២ : បរិមាណចំណីផ្តល់អោយត្រីស៊ី ........ ១៨
តារាង ៣ : កត់ត្រាការប្រមូលផលត្រី ........ ៣១
តារាង ៤ : ការកត់ត្រាលើមុខចំណាយផ្សេងៗ ........ ៣១

## **កំណត់សំគាល់:**

ម : អក្សរសរសេរកាត់ អានថា *ម៉ែត្រ*

ស.ម : អក្សរសរសេរកាត់ អានថា *សង្ទីម៉ែត្រ*

គ.ក្រ : អក្សរសរសេរកាត់ អានថា *គីឡូក្រាម*

ម២ : អក្សរសរសេរកាត់ អានថា *ម៉ែត្រក្រឡា ឬ ម៉ែត្រការេ (១ ម៉ែត្របួនជ្រុង)*

## **ខ្នាតដែលកសិករធំលាប់ប្រើ:**

១ លី = ១ មីល្លីម៉ែត្រ  ១ ហ៊ុន = ១ សង្ទីម៉ែត្រ  ១ តឹក = ១០ សង្ទីម៉ែត្រ

១ ខាំ = ១០០ ក្រាម  ១០០ សង់ទីម៉ែត្រ = ១ ម៉ែត្រ  ១០០០ ក្រាម = ១ គីឡូក្រាម

## **ពន្យល់ន័យ:**

- *ម៉ែត្រការេ:* មួយម៉ែត្របួនជ្រុង
- *បួង់តុង:* គឺ ជាពពួកសត្វ ឬ រុក្ខជាតិល្អិតៗដែលរស់នៅក្នុងទឹក ។
- *បួង់តុងសត្វ-បួង់តុងរុក្ខជាតិ (ឬ ចំណីធម្មជាតិ):* វាកើតឡើងក្រោយពេលដាក់ជីលាមកសត្វ - រុក្ខជាតិ និងបញ្ចូលទឹក (រយៈពេលពី ៤ - ៥ ថ្ងៃ) ។
- *កំបោរសមានគុណភាព*: គឺប្រភេទកំបោរដែលរាយ(ផុស)ហើយដាក់ចូលក្នុងទឹកវាមានប្រតិកម្ម (ពុះ) ។
- *ត្រីពុល*:ដោយសារទឹកក្នុងស្រះខ្វះអុកស៊ីហ្សែន ឬ ទឹកស្រះគ្មានគុណភាព និង បរិមាណត្រីសមស្រប ។
- *ចំណីកែច្នៃ*: ជាចំណីដែលផ្សំពីធាតុមួយចំនួនចូលគ្នា ដូចជា កន្ទក់, ម្សៅពោត, ចុងអង្ករ, ម្សៅដំឡូង ។ល ។
- *ប្រភេទត្រីក្រៅស្រុក:* ជាប្រភេទត្រីនាំចូលពីប្រទេសខាងក្រៅមកចូលក្នុងស្រុក (ពូជក្រៅស្រុក) ។
- *ស៊ីចំណីចំរុះ:* ស៊ីសាច់ រុក្ខជាតិ កាកសំណល់ ចំណីកែច្នៃ លាមកសត្វជាអាហារ ។
- *ស្រះថ្មី:* ស្រះទើបនឹងជីករួច មិនទាន់ស្តុកទឹកបានមួយរដូវវស្សា ។
- *ហាលបាតស្រះ:* ពង្រីងទឹកអោយរីងពីបាតស្រះ ទុកអោយបាតស្រះស្ងួត ។
- *បាចកំបោរស (កំបោរលាបរបងផ្ទះ ឬ ជញ្ជាំងផ្ទះ):* បាចកំបោរក្រោយពេលពង្រីងស្រះ (ភក់នៅសើម) ។ បាចកំបោរនៅពេលថ្ងៃក្តៅ (មេឃគ្មានភ្លៀង) ។
- *ហាប៉ា (ស្បៃមុង):* មុងសំរាប់ដាក់កូនត្រី ដែលធ្វើពីសាច់ក្រណាត់ ឬ សាច់ស្បៃមុង ។
- *ពពួកបរាសិត:* ជាកូនសត្វតូច ខាំតោងជាប់នឹងខ្លួនត្រី ។
- *ពណ៌ទឹកមានគុណភាព:* ទឹកមានគុណភាពមានពណ៌ត្នោតខ្ចី ឬ ពណ៌ស្លឹកចេកខ្ចី ឬ ពណ៌សំបកសណ្តែកខៀវ ។
- *ហាលថ្ងៃបាតស្រះ :* ស្រះក្រោយពេលពង្រីករួច ត្រូវបាចកំបោរ មិនអោយទឹកហូរចូលក្នុងស្រះ ។

# សេចក្តីផ្តើម

សាច់ត្រីជាប្រភពម្ហូបអាហារមានជីវជាតិខ្ពស់ និងមានសារៈសំខាន់បំផុតក្នុងការជួយជីវភាពប្រចាំថ្ងៃរបស់មនុស្ស។ សាច់ត្រីសំបូរជីវជាតិប្រូតេអ៊ីនខ្ពស់ជួយដល់ប្រព័ន្ធរំលាយអាហារ និងធ្លងផុតនូវជំងឺមួយចំនួន។ យើងអាចកែច្នៃសាច់ត្រីជាម្ហូបអាហារសំរាប់បរិភោគ ម្សៅត្រី ខ្លាញ់ត្រី និងកែច្នៃ ធ្វើជាឱសថសំរាប់ព្យាបាលជំងឺមួយចំនួន។ ល។

បច្ចុប្បន្ននេះ បរិមាណត្រីនៅក្នុងធម្មជាតិកាន់តែថយចុះជាលំដាប់ ដោយសារបំរែបំរួលនៃធម្មជាតិ និងការគំរាមកំហែងពីសំណាក់មនុស្សដូចជា ការប្រើថ្នាំពុល ជីគីមី ការប្រើឧបករណ៍នេសាទហាមឃាត់ ការឆ្ការព្រៃលិចទឹកយកដីធ្វើស្រែ ការចាក់ដីលប់ជំរកត្រីធ្វើជាលំនៅដ្ឋាន និងការកើនឡើងជាលំដាប់ពីកំណើនមនុស្ស។ ក្រៅពីផលនេសាទត្រីទឹកសាប និង ទឹកប្រៃ មានតែការចិញ្ចឹមត្រីទេដែលអាចកាត់បន្ថយការនេសាទត្រីធម្មជាតិ និងជួយបំពេញតំរូវការហូបចុកដល់ប្រជាពលរដ្ឋ។

ដើម្បីចូលរួមចំណែកក្នុងការលើកកំពស់ក៏រិតជីវភាព ជាពិសេសម្ហូបអាហារប្រចាំថ្ងៃ ខ្ញុំបានប្រមូលផ្តុំនូវបច្ចេកទេស បទពិសោធន៍ និងការដកស្រង់បទពិសោធន៍ពីកសិករចិញ្ចឹមត្រីយកមកចងក្រងជាសៀវភៅនេះ ដែលមានឈ្មោះថា: "**បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ**" ។

សៀវភៅនេះ នឹងជួយដល់កសិករពីបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះ និងចិញ្ចឹមត្រីក្នុងស្រែ (ត្រី - ស្រូវ)។ ការណែនាំក្នុងសៀវភៅនេះ ផ្តោតទៅលើបច្ចេកទេសសាមញ្ញៗដែលយើងមិនបានចាប់អារម្មណ៍ដូចជា ការរៀបចំស្រះ ចរិតរស់នៅរបស់ត្រី របៀបអោយចំណី ការថែទាំ និងទីតាំងសមស្របទៅនឹងការចិញ្ចឹមត្រី។

ខ្លឹមសារក្នុងសៀវភៅនេះនឹងជួយណែនាំបង្ហាញប្រាប់ពីមូលដ្ឋានគ្រឹះសំខាន់ៗ និងជួយបំភ្លឺផ្លូវដែលអ្នកបានជួបនូវបញ្ហាក្នុងការចិញ្ចឹមត្រី ហើយអាចកែនូវចំនុចខ្វះខាតណាមួយ ដើម្បីអោយទិន្នផលត្រីបានខ្ពស់ជាងមុន។

## ១. ហេតុអ្វីបានជាយើងចាំបាច់ចិញ្ចឹមត្រី ?

ទំនៀមទំលាប់កសិករខ្មែរជីកស្រះយកដីដាក់ភូមិ ឬ សួនបន្លែ រីឯស្រះរក្សាទឹក សំរាប់ប្រើប្រាស់ក្នុងគ្រួសារ និងនៅចុងរដូវប្រាំង គេអាចប្រមូលផលត្រីធម្មជាតិបានពីស្រះថែមទៀតផង។ ក្រោយមកដោយមានការគំរាមកំហែងពីមនុស្ស និងការប្រែប្រួលធម្មជាតិបានធ្វើអោយត្រីធម្មជាតិថយចុះ។ ឥឡូវនេះ យើងជំរុញអោយកសិករមានការគិតដល់របៀបចិញ្ចឹមត្រីដូចជា រៀបចំសំអាតស្រះ ផ្តល់ចំណី បន្ថែមពូជត្រី និងបង្កើតបរិស្ថានល្អដល់ជំរកត្រីដើម្បីអោយត្រីមានការលូតលាស់ និងធំធាត់លឿន។ តាមការយល់ដឹងរបស់កសិករផលប្រយោជន៍នៃការចិញ្ចឹមត្រីមានដូចខាងក្រោមៈ

- ដោះស្រាយម្ហូបបានទាន់ចិត្ត និងកាត់បន្ថយការចំណាយប្រាក់ក្នុងគ្រួសារ
- ការពារដំណាំស្រូវ និងស៊ីសត្វល្អិតក្នុងស្រែ
- មិនចំណាយថវិកាទិញត្រីហូប និងអាចជួយបង្កើនប្រាក់ចំណូលតាមគ្រួសារ
- កាត់បន្ថយការចាប់ត្រីធម្មជាតិបានមួយកំរិត
- កាត់បន្ថយការនាំត្រីទីផ្សារក្រៅស្រុកចូលមកក្នុងស្រុក
- បង្កើនសុខមាលភាពដល់គ្រួសារ
- ពង្រីកកសិដ្ឋានដាំដុះ និងស្រះចិញ្ចឹមត្រី

## ២. ចរិតរស់នៅនៃប្រភេទត្រីចិញ្ចឹមមួយចំនួន

ចិញ្ចឹមត្រីក្នុងស្រះ ឬ ស្រែ គប្បីជ្រើសរើសប្រភេទត្រីណាដែលសំខាន់ជាងគេក្នុងបណ្តាប្រភេទត្រីដាក់ចិញ្ចឹម ជាពិសេសជ្រើសរើសប្រភេទត្រីដែលចរិតរស់នៅស៊ីចំណីចំរុះ និងងាយចិញ្ចឹម។

### ២.១. ប្រភេទត្រីក្រៅស្រុក

#### ក. ត្រីកាបស



រូបភាព ១ : ត្រីកាបស

♦ រស់នៅ រកចំណីស៊ីផ្ទៃលើ និងកណ្តាលនៃផ្ទៃទឹក

♦ ស៊ីចំណី កន្ទក់ ម្សៅពោត ជាពិសេស ឬង់តុងរុក្ខជាតិ

♦ ការលូតលាស់លឿន ត្រីញីធំជាងត្រីឈ្មោល

♦ មិនទំលាក់ពងក្នុងស្រះ ប្រឡាយ (បើគ្មានចរន្តទឹកហូរ) ជាប្រភេទត្រីពងលិចអណ្តែត

♦ ចិញ្ចឹម ១ ឆ្នាំ បានទំងន់ ពី ០,៨ - ១,៥ គីឡូក្រាមក្នុង ១ ក្បាល ។

## ខ. ត្រីកាបសាមញ្ញ



**រូបភាព ២ : ត្រីកាបសាមញ្ញ**

♦ រស់នៅ រកចំណីស៊ីស្រទាប់បាតនៃទឹកស្រះ

♦ ការលូតលាស់លឿន

♦ ស៊ីចំណីចំរុះ ដូចជា ជន្លេន ខ្យង សត្វឬង់តុង កន្ទក់ ពោត សំណែក ស្រូវបណ្តុះ បន្លែ ចកបាយទា ចកពងទឹក ត្រកួន និងកាកសំណល់ផ្ទះបាយ ។

♦ ត្រីញីធំជាងត្រីឈ្មោល

♦ ត្រីពងក្នុងស្រះ ឬ ប្រឡាយ ពេលមានភ្លៀងធ្លាក់ធំ ឬ បញ្ចូលទឹក

♦ ជាប្រភេទត្រីពងស្អិត (តោង) ជាប់នឹងរុក្ខជាតិក្នុងទឹក

♦ ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ០,៥ - ១ គីឡូក្រាមក្នុង ១ ក្បាល ។

## គ. ត្រីកាបផល្លា (ត្រីឃ្លោល)



រូបភាព ៣ : ត្រីកាបផល្លា (ត្រីឃ្លោល)

- រស់នៅ រកចំណីស៊ីនៅស្រទាប់បាតនៃទឹកស្រះ
- ធន់នឹងជំងឺ, សីតុណ្ហភាព និងការលូតលាស់លឿន
- ស៊ីចំណីចំរុះ ដូចជា កន្ទក់ ពោត ពន្លកគ្រាប់ ឬ មើមរុក្ខជាតិ សណ្តែក ចកបាយទា ចកពងទឹក សត្វល្អិត១ក្នុងទឹក រុក្ខជាតិរលួយនៅបាតស្រះ និងកាកសំណល់ផ្ទះបាយ
- ត្រីញី និងត្រីឈ្មោលធំប្រហាក់ប្រហែលគ្នា
- ត្រីពងក្នុងស្រះ ឬ ប្រឡាយ បញ្ចូលទឹកពេលព្រលប់
- ជាប្រភេទត្រីពងលិចអណ្តែតក្នុងទឹក
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ០,៨ - ១,៨ គីឡូក្រាមក្នុង ១ ក្បាល ។

## ២.២. ប្រភេទត្រីក្នុងស្រុក

### ក. ត្រីឆ្ពិន



រូបភាព ៤ ៖ ត្រីឆ្ពិន

- រស់នៅ រកចំណីស៊ីផ្ទៃលើ និងកណ្ដាលនៃទឹកស្រះ
- ស៊ីចំណីភាគច្រើនជាប្រភេទរុក្ខជាតិ ដូចជា ស្លែ ត្រកួន ចកបាយទា ស្លឹកកន្ទំថេត ស្លឹកអង្គាដី ជន្ទល់ភ្នំ កំពឹងពួយ សារាយ កន្ទក់ ចុងអង្ករ ពោត សណ្ដែក ស្រូវបណ្ដុះ កណ្ដៀវ កាកសំណល់ផ្ទះបាយ លាមកគោក្របី ជ្រូក មាន់។ល។
- ងាយចិញ្ចឹមក្នុងស្រះ ស្រែ ប្រឡាយ
- ត្រីញីធំជាងត្រីឈ្មោល ជាប្រភេទត្រីពងលិចអណ្ដែត
- ពងក្នុងស្រះ ឬ ប្រឡាយ (ពេលមានភ្លៀងធ្លាក់ធំ ឬ បញ្ចូលទឹកពេលព្រលប់)
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ០,៣ - ០,៥ គីឡូក្រាមក្នុង ១ ក្បាល ។

### ខ. ត្រីកន្ធរ



រូបភាព ៥ ៖ ត្រីកន្ធរ

- រស់នៅ រកចំណីស៊ីនៅផ្ទៃលើ កណ្ដាល និងបាតនៃទឹកស្រះ
- ស៊ីចំណីភាគច្រើនជាសារធាតុរលួយនៅបាតស្រះ ស្លែ ឬ រុក្ខជាតិរលួយក្នុងស្រះ
- ក្រៅពីនេះវាស៊ី កន្ទក់ ចុងអង្ករ ពោត និងកាកសំណល់ផ្ទះបាយ ឬ លាមកជ្រូក
- ចូលចិត្តរស់នៅកន្លែងណាទឹកមានសារធាតុរលួយ ( ស្មៅ ត្រកួន កំប្លោក ។ល។)
- ពងក្នុងស្រះ ឬ ប្រឡាយដែលមានរុក្ខជាតិដុះ , ពងវាអណ្តែតជាប់នឹងពពុះទឹក
- ធន់នឹងមជ្ឈដ្ឋានទឹកដែលមានសារធាតុរុក្ខជាតិរលួយ និងជំងឺ
- ងាយចិញ្ចឹមក្នុងស្រះ ស្រែ ប្រឡាយ
- ពងក្នុងស្រះ ស្រែ ប្រឡាយ ( ធ្វើសំបុកជាពពុះទឹក មុននឹងពង)
- ជាប្រភេទត្រីពងអណ្តែតលើផ្ទៃទឹក
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ១ - ២ ខាំ ក្នុង ១ ក្បាល ។

## គ. ត្រីប្រា



**រូបភាព ៦ : ត្រីប្រា**

- រស់នៅស្រទាប់ផ្ទៃកណ្ដាល និងបាតនៃទឹកស្រះ
- ជាប្រភេទត្រីស៊ីចំណីចំរុះ កន្ទក់ ចុងអង្ករ ពោត សាច់ត្រី ចក និងកាកសំណល់ផ្ទះបាយ ។ល។
- ធន់នឹងមជ្ឈដ្ឋានទឹករស់នៅ និងធន់ជំងឺ
- មិនទំលាក់ពងក្នុងស្រះ
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ០,៨ - ១,៨ គីឡូក្រាមក្នុង ១ ក្បាល ។

## ៣. ធនធាន និងកត្តាជាមូលដ្ឋានក្នុងការចិញ្ចឹមត្រី

ការចិញ្ចឹមត្រីផ្អែកលើធនធាន និងកត្តាមួយចំនួន ដូចជា បច្ចេកទេស កូនត្រីពូជ ប្រភពទឹក ចំណី ដីជីកស្រះ ទុន ពលកម្ម ។ល។ ដូច្នេះ ដើម្បីទទួលបានផលត្រីល្អ អ្នកចិញ្ចឹមត្រីគប្បីស្វែងយល់ចំនុចមួយចំនួនដូចខាងក្រោមៈ




**រូបភាព ៧ : ធនធាន និងកត្តាជាមូលដ្ឋានក្នុងការចិញ្ចឹមត្រី**

## ៤. ប្រភពទឹក

ប្រភពទឹកជាកត្តាសំខាន់បំផុតក្នុងការជ្រើសរើសកន្លែងជីកស្រះ និងផ្គត់ផ្គង់ទឹកក្នុងការចិញ្ចឹមត្រី ។

### ក. វិធីត្រួតពិនិត្យគុណភាពទឹក

មុនដាក់ត្រីចិញ្ចឹមត្រូវត្រួតពិនិត្យមើលគុណភាពទឹកជាមុនសិន មានរបៀបសាមញ្ញៗដែលកសិករងាយអនុវត្តបានដូចជា:

☞ <u>ជ្រលក់ចង្អុលដៃ</u>

យកចង្អុលដៃជ្រលក់ក្នុងទឹកស្រះដែលបំរុងដាក់ត្រីចិញ្ចឹមរួចលិទ្ធ បើសិនជាលិទ្ធទឹកមានជាតិជូរគឺទឹកនោះមិនអាចចិញ្ចឹមត្រីបានទេពីព្រោះ ពិបាកបង្កើតចំណីធម្មជាតិ ត្រីលូតលាស់យឺត និងត្រីងាយកើតជំងឺ ។



☞ <u>ទឹកម្លូរហ្លួប</u>

ប្រើទឹកម្លូរហ្លួបបន្តក់ចូលទឹកស្រះ បើសិនទឹកស្រះមានពណ៌ក្រហមដដែលគឺ ទឹកល្អ ។ បើសិនទឹកមានពណ៌ខ្មៅគឺមិនល្អមិនអាចចិញ្ចឹមត្រី (ទឹកជូរ)ពីព្រោះទឹកពិបាកបង្កើតចំណីធម្មជាតិ ត្រីលូតលាស់យឺត និងត្រីងាយកើតជំងឺ ។



☞ <u>ប្រើសាប៊ូបោកខោអាវ</u>

យកទឹកស្រះចាក់ចូលក្នុងកាធុន ចាក់សាប៊ូចូលយកដៃកូរ ។ បើសិនទឹកមានពពុះច្រើន ហើយឆាប់អស់ពពុះ គឺទឹកអាចចិញ្ចឹមត្រីបាន ។ តែបើសិនទឹកមានពពុះតិចនោះទឹកក្នុងស្រះចិញ្ចឹមត្រីមិនល្អពីព្រោះទឹកមានជាតិជូរវាពិបាកក្នុងការបង្កើតចំណីធម្មជាតិ និងធ្វើអោយត្រីលូតលាស់យឺត និងត្រីងាយកើតជំងឺ ។




**រូបភាព ៨ ៖ របៀបពិនិត្យគុណភាពទឹកស្រះមុនដាក់ត្រីចិញ្ចឹម**

ខ. <u>គុណភាពទឹក:</u> ស្រះចិញ្ចឹមត្រីទឹកមានគុណភាពល្អដែលមានជាតិជូរ ឬប្រៃតិចបំផុត។

គ. <u>ជំរៅទឹក:</u> ពន្លឺចាំងចូលក្នុងទឹកមានកំរិតថ្នាទឹកស្រះពី ៣ - ៤ តឹក។ ចំណាំងពន្លឺព្រះអាទិត្យចូលក្នុងទឹកស្រះអាស្រ័យទឹងការកកើតប្លង់តុង និងកំរិតថ្នានៃទឹកស្រះ។ ជំរៅទឹកស្រះពី ២ - ៣ ម៉ែត្រ។

## ៥. ការរៀបចំកន្លែងចិញ្ចឹមត្រី

### ៥.១. ជ្រើសរើសទីតាំងជីកស្រះ ឬ ប្រឡាយ

ការជីកប្រឡាយក្នុងស្រែ និងជីកស្រះគួរមានលក្ខណៈសមស្របដូចខាងក្រោម:

- នៅក្បែរផ្ទះ ងាយស្រួលការពារ និងថែរក្សា
- ដីមានកំរិតជ្រាបទឹកតិច ឬ បាតស្រះជាប្រភេទដីឥដ្ឋ (ដក់ទឹកបានយូរ)
- គ្មានសារធាតុពុលហូរចូល
- ស្រះទទួលពន្លឺថ្ងៃគ្រប់គ្រាន់ (គ្មានដើមឈើធំៗ នៅជុំវិញស្រះ)
- មិនលិចទឹកនៅរដូវវស្សា

### ៥.២. របៀបជីកស្រះ ឬ ប្រឡាយ

មុនពេលជីកស្រះចិញ្ចឹមត្រីជំហានដំបូងត្រូវពិនិត្យគុណភាពដីសិន :

☞ យើងជីកដីជំរៅ ១ ម៉ែត្រ រួចយកដីសើមមួយក្តាប់ពូតរួចបោះទៅលើ។ បើសិនដីនោះធ្លាក់មិនបែកជាកំទេចតូចៗ គឺដីនោះល្អ (ជីកស្រះដក់ទឹកបានយូរ)។ បើសិនដីធ្លាក់បែកជាកំទេចតូចៗ គឺជ្រាបទឹក ជីកស្រះចិញ្ចឹមមិនបានរយៈពេលយូរ ព្រោះឆាប់រីង (មិនដក់ទឹក)។ បើសិនជាកន្លែងជីកស្រះ ជាប្រភេទដីខ្សាច់ យើងយកដីឥដ្ឋមកទ្រាប់បាតស្រះ។



រូបភាព ៩ : ពិនិត្យគុណភាពដី ដើម្បីជីកស្រះចិញ្ចឹមត្រី

## ក. របៀបជីកស្រះ

គប្បីជីកស្រះរាងជាចតុកោណកែង ឬ រាងជាការេ (ទទឹងមិនគួរលើសពី ៣០ ម៉ែត្រ) ដើម្បីងាយអូសចាប់ត្រី ។ ទំហំស្រះពី ១០០ - ៥០០ ម៉ែត្រការេ ឬ ៣.០០០ ម៉ែត្រការេ និងជំរៅស្រះពី ២ - ៣ ម៉ែត្រ ។ កំពស់ភ្លឺស្រះ ៦ តឹក ទៅ ៨ តឹក ។ ជញ្ជាំងស្រះមានជើងទេរ (មិនចោតចុះពេក) ។ បាតស្រះ ឬ ប្រឡាយរាបស្មើតែជំរាលមករង្វះបញ្ចេញបញ្ចូលទឹក ។




**រូបភាព ១០ : គំនូសកាត់ទទឹងស្រះ (មើលពីចំហៀងស្រះ)**

## ខ. របៀបជីកប្រឡាយក្នុងស្រែ

ជីកប្រឡាយទទឹងមាត់លើពី ១,៥ - ២ ម៉ែត្រ និងទទឹងបាតប្រឡាយពី ១ - ១,៥ ម៉ែត្រ ហើយជំរៅប្រឡាយពី ០,៥ - ១ ម៉ែត្រ ។ ជញ្ជាំងប្រឡាយមានជើងទេរ (មិនចោតចុះពេក) ។ ទំនប់មេកំពស់ ៦ តឹក ទៅ ៨ តឹក និងកំពស់ទំនប់កូនពី ២ - ៣ តឹក (ងាយអោយត្រីចេញចូលពីស្រែមកក្នុងប្រឡាយ) ។ បាតប្រឡាយរាបតែទេរមករករង្វះបញ្ចេញបញ្ចូលទឹក ។ ការជីកប្រឡាយក្នុងស្រែមានទំហំពី ១០ - ២០ ភាគរយ ធៀបនឹងផ្ទៃស្រែទាំងមូល ។ នៅលើខ្នងទំនប់គេគួរដាំបន្លែ ដូចជា ស្ពៃ ត្រកួន ប៉េងប៉ោះ ជីឡូងជ្វា កន្ទំថេត អង្គាដី ធ្វើជាចំណីត្រី ។




រូបភាព ១១ : គំនូសកាត់ទទឹងប្រឡាយ (មើលពីទំហៀងប្រឡាយ)

## ៥.៣. របៀបរៀបចំប្រឡាយ ឬ ស្រះថ្មី

យកដីស្រែស្រទាប់លើដាក់បាតស្រះ ឬ ប្រឡាយ រួចបញ្ចូលទឹកអោយលិចអាចម៍ដីបាតស្រះ ឬ ប្រឡាយ ហើយត្រាំទុកពី ៣ - ៤ ថ្ងៃ បង្កើតអោយមានភក់ខ្លះ ដើម្បីងាយកើតចំណីធម្មជាតិក្រោយពីដាក់ជីលាមកសត្វ និងរុក្ខជាតិ។ បន្ទាប់មកយកទឹកចេញរួចបាចកំបោរសភ្លាម (ដើម្បីអោយកំបោរមានប្រតិកម្មជាមួយភក់)ពី ៥ - ១០ គីឡូក្រាម ក្នុង ១០០ ម៉ែត្រការេនៃផ្ទៃស្រះ។ ហាលបាតស្រះ ឬ ប្រឡាយពី ១ - ២ ថ្ងៃ ដើម្បីកាត់បន្ថយជាតិជូរ ឬ ប្រៃនៅក្នុងស្រះ ធ្វើអោយទឹកងាយថ្លា ងាយដល់ការបង្កើតចំណីធម្មជាតិ។

ដាក់ជីលាមកសត្វ និងរុក្ខជាតិទ្រាប់បាតស្រះ ឬ ប្រឡាយ ក្នុង ១០០ ម៉ែត្រការេនៃផ្ទៃស្រះ រួមមានៈ

- អាចម៍គោ ឬក្របី : ៣០ - ៤០ គីឡូក្រាម
- អាចម៍មាន់ (បើមាន) : ២ - ៣ គីឡូក្រាម
- ទន្ទ្រានខែត្រ (ចងជាបាច់) : ២០ - ៣០ គីឡូក្រាម



រូបភាព ១២ : ដាក់ជីលាមកសត្វទ្រាប់បាតប្រឡាយ

ក្រោយពីដាក់ជីទ្រាប់បាតស្រះរួចបញ្ចូលទឹកក្នុងស្រះមានកំពស់ទឹក ៥ តឹក ហើយត្រាំទុកពី ៣ - ៥ ថ្ងៃ ឬ ១ អាទិត្យ ដើម្បីបង្កើតមេចំណីធម្មជាតិ។ ចុងក្រោយបន្ថែមទឹកចូលស្រះ ឬ ប្រឡាយ តាមតំរូវការទុកបានពី ៤ - ៥ ថ្ងៃ យើងសង្កេតឃើញទឹកមានពណ៌បៃតង (ចំណីធម្មជាតិកើត) ទើបលែងកូនត្រី។

## ៥.៤. របៀបរៀបចំប្រឡាយ ឬ ស្រះចាស់

ដំបូងពង្រីងទឹកអោយអស់ពីបាតស្រះប្រមូលត្រីចេញ។ សំអាតស្មៅ ឬ រុក្ខជាតិដែលដុះជុំវិញមាត់ស្រះ ឬ ប្រឡាយ។ ជួសជុលទំនប់ ជញ្ជាំង និងបាតស្រះ ឬ ប្រឡាយអោយកំនើនភាពរឹងមាំ។ ស្តារ និងសំអាតបាតស្រះ ឬ ប្រឡាយ។ រក្សាភក់ចាស់បាតស្រះកំរាស់ពី ២ - ៣ តឹក រួចបាចកំបោរសពី ៣ - ៥ គីឡូក្រាមក្នុង ១០០ ម៉ែត្រការេ។ ហាលបាតស្រះ ឬ ប្រឡាយពី ១ - ២ ថ្ងៃ ឬ ១ អាទិត្យ ដើម្បីកាត់បន្ថយជាតិជូរ ឬ ប្រៃ សំលាប់មេរោគ ធ្វើអោយទឹកងាយថ្លា ហើយចំណីធម្មជាតិងាយកើត។

ដាក់ជីលាមកសត្វ និងរុក្ខជាតិទ្រាប់បាតស្រះ ឬ ប្រឡាយ ក្នុង ១០០ ម៉ែត្រការេនៃផ្ទៃស្រះ រួមមានៈ

- អាចម៍គោ ឬក្របី : ៣០ គីឡូក្រាម
- អាចម៍មាន់ (បើមាន) : ២ - ៣ គីឡូក្រាម
- ទន្ទ្រានខែត្រ (ចងជាបាច់) : ២០ គីឡូក្រាម



**រូបភាព ១៣ : បាចកំបោរស រួចបោសផ្ទៃបាតស្រះ**

ក្រោយពីដាក់ជីទ្រាប់បាតស្រះរួចបញ្ចូលទឹកក្នុងស្រះកំរិតទឹក ៥ តឹក ហើយរក្សាទឹកពី ៣ - ៥ ថ្ងៃ ឬ ១ អាទិត្យ។ ចុងក្រោយបន្ថែមទឹកចូលស្រះ ឬ ប្រឡាយ តាមតំរូវការ។ ក្រោយពីបានពី ៤ - ៥ ថ្ងៃ យើងសង្កេតឃើញទឹកពណ៌បៃតង (ចំណីធម្មជាតិកើត) ទើបដាក់កូនត្រីចិញ្ចឹម។

## ៦. ពេលវេលានៃការលែងកូនត្រីចិញ្ចឹម

ដើមរដូវវស្សា នៅតាមតំបន់មួយមានទឹកនៅតាមវាលស្រែ និងស្រះ បង្កលក្ខណៈអំណោយផលដល់ការចិញ្ចឹមត្រីនៅតាមតំបន់នោះ ។ ប៉ុន្តែទន្ទឹមនឹងនេះ វាក៏ជាផលវិបាកមួយដែរ ប្រសិនជាដាក់ត្រីចិញ្ចឹមមានការយឺតយ៉ាវនោះនឹងធ្វើអោយអត្រាបាត់បង់កូនត្រីខ្ពស់។ ដូចនេះ ដើម្បីកាត់បន្ថយការបាត់បង់កូនត្រី គប្បីលែងកូនត្រីនៅដើមរដូវវស្សា ពីព្រោះពពួកបំផ្លាញកូនត្រីមិនទាន់កើតច្រើន ដូចជា ពពួកត្រីកាច អន្ទង់ ក្តាម កង្កែប កន្លង់ ។ល។ ដូចនេះ យើងគប្បីរៀបចំការងារមួយចំនួនក្នុងការដាក់ត្រីចិញ្ចឹមដូចខាងក្រោមៈ

### ៦.១ របៀបដឹកកូនត្រីធូជ

ដើម្បីកាត់បន្ថយអត្រាងាប់របស់កូនត្រីពេលដឹកជញ្ជូន គប្បីរៀបចំតាមជំហាន ដូចខាងក្រោមៈ

● **ជំហានទី ១ :** មុនពេលអូសចាប់កូនត្រី ជាដំបូងត្រូវបង្វឹកកូនត្រីពី ២ - ៣ ថ្ងៃជាមុនសិន។ បង្វឹកកូនត្រី ១ ដង ក្នុង ១ ថ្ងៃ ដោយប្រើអួន អញ្ចង កៀរនៅល្ងាចទឹកត្រជាក់ និងមុនពេលដាក់ចំណី។ គេត្រូវផ្អាកអោយចំណីចំនួន ២ ថ្ងៃ មុនពេលកៀរកូនត្រីដាក់ក្នុងហាប៉ា (ស្តុកកូនត្រី)។

- **ជំហានទី ២** : កៀរកូនត្រីដាក់ក្នុងហាប៉ាដែលមានទឹកស្អាត។ ស្តុកកូនត្រីក្នុងហាប៉ា រយៈពេលតិចបំផុត ២៤ ម៉ោង មុនពេលដឹកជញ្ជូនទៅកន្លែងចិញ្ចឹម ដើម្បីអោយកូនត្រីទំលាក់លាមក ជៀសវាងនៅពេលដឹកជញ្ជូនមានលាមក ក្នុងថង់ច្រើន វាធ្វើអោយកូនត្រីពុល និងងាប់។



**រូបភាព ១៤ : បង្ហីកកូនត្រីពូជ មុនពេលកៀរដាក់ក្នុងហាប៉ា**



**រូបភាព ១៥ : បន្សាំកូនត្រីក្នុងហាប៉ាមុនពេលដឹកជញ្ជូន (រយៈពេល ២៤ ម៉ោង)**

### ក. ដឹកជញ្ជូនបិទជិត (ថង់ផ្លាស្ទិក)

ថង់ដាក់កូនត្រីមានទំហំ ១០ តឹក គុណ ៦ តឹក។ ទឹកដាក់ក្នុងថង់ស្មើនឹង ១ ភាគ ៣ នៃមាឌថង់ រួចដាក់កូនត្រីក្នុងថង់ បន្ទាប់មកបញ្ចូលខ្យល់អុកស៊ីហ្សែន។ ចំនួនកូនត្រីស្តុកក្នុងថង់អាស្រ័យនឹងទំហំកូនត្រី ឬ ប្រវែងកូនត្រី (កូនត្រីតូច ឬ ធំ)។

ឧបករណ៍សំរាប់ដាក់កូនត្រីក្នុងការដឹកជញ្ជូនទៅកន្លែងចិញ្ចឹម ដូចជា ថងប្លាស្ទិក កាន ធុងជ័រ ....។



**រូបភាព ១៦ : ដាក់កូនត្រីក្នុងថង់ប្លាស្ទិក កានជ័រ ធោ៊ត**

- កូនត្រីស្តុកពី ៣០០ - ៥០០ ក្បាល ក្នុង ១ ថង់ ប្រវែងកូនត្រីពី ២ - ៣ ហ៊ុន
- កូនត្រីស្តុកពី ២០០ - ៣០០ ក្បាល ក្នុង ១ ថង់ ប្រវែងកូនត្រីពី ៤ - ៦ ហ៊ុន
- រយៈពេលដឹកកូនត្រីពី ៣ - ៤ ម៉ោង (ពេលដឹកត្រូវគ្របការពារកំដៅថ្ងៃ) បើសិនលើសម៉ោងនេះ ឬ ថង់កូនត្រីធូរខ្យល់ (ខ្យល់ថយ) ត្រូវប្តូរទឹក និងបញ្ចូលខ្យល់សារជាថ្មី។

### ខ. ដឹកជញ្ជូនចំហ (ធុងជ័រ ធោ៊ត កានជ័រ...)

ការដឹកដោយចំហបានតែនៅកន្លែងជិត១ដូចជា ពីកន្លែងបន្សាំកូនត្រី ឬ កន្លែងស្ថានីយ៍ផលិតពូជទៅកន្លែងចិញ្ចឹម។

- ប្រវែងដងខ្លួនកូនត្រី ១ ហ៊ុន ចំនួនកូនត្រី ៣០០ ក្បាល ក្នុង ១ លីត្រទឹក
- ប្រវែងដងខ្លួនកូនត្រី ២ ហ៊ុន ចំនួនកូនត្រី ១៣០ ក្បាល ក្នុង ១ លីត្រទឹក
- ប្រវែងដងខ្លួនកូនត្រី ៣ ហ៊ុន ចំនួនកូនត្រី ៤០ ក្បាល ក្នុង ១ លីត្រទឹក
- ប្រវែងដងខ្លួនកូនត្រី ៤ ហ៊ុន ចំនួនកូនត្រី ២០ ក្បាល ក្នុង ១ លីត្រទឹក

## ៦.២. របៀបលែងកូនត្រី

ដឹកជញ្ជូនកូនត្រីនៅពេលព្រឹកព្រលឹម ឬ នៅពេលថ្ងៃជិតលិច។ មុននឹងលែងកូនត្រីចូលក្នុងស្រះត្រូវដាក់ត្រាំក្នុងទឹកស្រះ ឬ ប្រឡាយពី ១៥ - ២០ នាទី ដើម្បីអោយសីតុណ្ហភាពខាងក្រៅ និងក្នុងថង់មានភាពប្រហាក់ប្រហែលគ្នា និងបន្ថយការនឿយហត់របស់ត្រី។

យកដៃកួរទឹកមុខមាត់ថង់ និងបាចទឹកខាងក្រៅចូលក្នុងថង់កូនត្រី អោយកូនត្រីហែលចេញតាមសំរួល។ គប្បីលែងកូនត្រីនៅម៉ោង ៨ ព្រឹក ឬ ម៉ោង ៦ ល្ងាច (សីតុណ្ហភាពទឹកទាប ឬ ទឹកត្រជាក់) ទើបកូនត្រីមានសុខភាពល្អ ឬ មិនងាប់ ។ កុំលែងកូនត្រីពេលមេឃកំពុងភ្លៀង ពីព្រោះទឹកភ្លៀងមានជាតិអាស៊ីតនៅស្រទាប់លើនៃផ្ទៃទឹកស្រះធ្វើអោយកូនត្រីងាប់។ អាចលែងកូនត្រីបានក្រោយពីភ្លៀងរាំងពី ២ - ៣ ម៉ោង ពីព្រោះទឹកស្រះបានលាយជាមួយទឹកភ្លៀងបន្ថយជាតិអាស៊ីតហើយកូនត្រីអាចធន់បាន។



**រូបភាព ១៧ : របៀបលែងកូនត្រី**

## ៦.៣. បរិមាណកូនត្រីដាក់ចិញ្ចឹម

ចំនួនកូនត្រីដាក់ចិញ្ចឹមយើងត្រូវដឹងប្រភេទត្រីដែលអាចពងកូនក្នុងស្រះ ប្រឡាយ ស្រែ មិនត្រូវដាក់ច្រើនពេកទេ។ កូនត្រីលែងចូលស្រះមានចំនួនសមស្របនោះត្រីធំធាត់លឿន តែបើសិនកូនត្រីលែងចំនួនច្រើនការផ្តល់ចំណីមិនគ្រប់គ្រាន់ ផ្ទៃស្រះតូចចង្អៀត ធ្វើអោយត្រីងាយពុល ងាយខ្វះខ្យល់ក្នុងទឹក ត្រីលូតលាស់យឺត។

តារាង ១ : ប្រភេទត្រីចិញ្ចឹមចំរុះ

| ប្រភេទត្រី | សមាមាត្រ (ភាគរយ) | ប្រវែងកូនត្រី |
|---|---|---|
| ឆ្ពិន | ៤០ | ៤ - ៦ ហ៊ុន |
| កាបស | ៣០ | |
| កាបសាមញ្ញ | ១០ | |
| កន្ធរ | ១០ | |
| ប្រា | ១០ | |



**រូបភាព ១៨ : វាស់ប្រវែងកូនត្រី**

ឧទាហរណ៍: ស្រះទំហំ ១០០ ម៉ែត្រការេ។ លែងកូនត្រី ៣ ក្បាល ក្នុង ១ ម៉ែត្រការេ។

ចំនួនកូនត្រីលែងចូលស្រះ សរុប = ៣០០ក្បាល :

| | | | |
|---|---|---|---|
| ត្រីឆ្ពិន | ៤០ | ភាគរយ ស្មើនឹង | ១២០ ក្បាល |
| ត្រីកាបស | ៣០ | ភាគរយ ស្មើនឹង | ៩០ ក្បាល |
| ត្រីកាបសាមញ្ញ | ១០ | ភាគរយ ស្មើនឹង | ៣០ ក្បាល |
| ត្រីកន្ធរ | ១០ | ភាគរយ ស្មើនឹង | ៣០ ក្បាល |
| ត្រីប្រា | ១០ | ភាគរយ ស្មើនឹង | ៣០ ក្បាល |

## ៧. ចំណីត្រី

ចំណីត្រី ដូចជា សារាយ ត្រកួន ចកពងទឹក ចកបាយទា ស្លែ ស្លឹកអង្គាដី ស្លឹកផ្លែកន្ទំថេត ពោត ផ្លែពុតទ្រា ជន្ទល់ភ្នំ ស្លឹកមើមដំឡូងជ្វា កន្ទក់ ចុងអង្ករ កណ្ដៀរ អង្រ្គង ដង្កូវ ជន្លេន កាកសំណល់ផ្ទះបាយ ជីកំប៉ុស្ដ ។ល។



**រូបភាព ១៩ : មិញ្ញាំចង្រ្ហៃឲ្យត្រីស៊ី**

## ក. ការផ្តល់ចំណី

ប្រភេទចំណីនីមួយៗមានសារៈសំខាន់ក្នុងការលូតលាស់របស់ត្រី ។ ដើម្បីអោយត្រីមានការលូតលាស់ល្អគួរផ្សំសមាសធាតុចំណី ដូចជា កន្ទក់ ៦០ ភាគរយ ចុងអង្ករ ២០ ភាគរយ បន្លែ ១៨ ភាគរយ អំបិល ២ ភាគរយ ។

ឧទាហរណ៏: ចំណីសរុប ១ គីឡូក្រាម មានសមាសធាតុផ្សំ ដូចខាងក្រោម:

- កន្ទក់ ៦០ ភាគរយ ស្មើនឹង ០,៦ គីឡូក្រាម នៃចំណីសរុប
- ចុងអង្ករ ២០ ភាគរយ ស្មើនឹង ០,២ គីឡូក្រាម នៃចំណីសរុប
- បន្លែ ១៨ ភាគរយ ស្មើនឹង ០,១៨ គីឡូក្រាម នៃចំណីសរុប
- អំបិល ២ ភាគរយ ស្មើនឹង ០,០២ គីឡូក្រាម នៃចំណីសរុប ។

( បើសិនធាតុផ្សំចំណីខាងលើនេះបានចំអិន គឺត្រីចូលចិត្ត និងធំលឿន )

អោយចំណីស៊ី ២ ដងក្នុង ១ ថ្ងៃ ( ម៉ោង ៨ ព្រឹក និង ម៉ោង ៥ ល្ងាច) ពីព្រោះទឹកត្រជាក់មិនធ្វើអោយប៉ះពាល់ដល់ការរំលាយអាហារ និងដកដង្ហើមរបស់ត្រី ។ បរិមាណចំណីអោយស៊ីស្មើនឹង ៣ ភាគរយ (សំរាប់ត្រីធំ)និងពី ៥ - ៧ ភាគរយ (សំរាប់កូនត្រី ) នៃទំងន់ខ្លួនត្រី ( មើលតារាង ២ ) ។

**តារាង ២: បរិមាណចំណីផ្តល់អោយត្រីស៊ី**

| ចំនួនត្រី | ទំងន់ត្រីក្នុង ១ ក្បាល | ចំណីអោយស៊ីក្នុង ១ ថ្ងៃ |
|---|---|---|
| កូនត្រី ៣០០ ក្បាល | ៥០ ក្រាម | ១ ថ្ងៃ អោយស៊ី ២ ដង ( ព្រឹក ០,៥ ខាំ និង ល្ងាច ០,៥ ខាំ) |
| ត្រីធំ ៣០០ ក្បាល | ៥ ខាំ | ១ ថ្ងៃ អោយស៊ី ២ ដង ( ព្រឹក ២ គ.ក្រ និង ល្ងាច ២ គ.ក្រ) |



**រូបភាព ២០ : ពិនិត្យចំណី និងបរិមាណត្រី**

## ខ. ទីកន្លែងអោយចំណី

- <u>កន្លែងដាក់ចំណី</u>: ធ្វើស៊ុមដាក់ចំណីនៅកន្លែងទឹករាក់ ៥ តឹក ដើម្បីងាយស្រួលអង្កេតមើលត្រី (ចំនួនត្រី និងសុខភាពត្រី) ។
- <u>ពេលវេលាផ្តល់ចំណី</u>: អោយចំណីត្រីស៊ីទៀងទាត់គឺព្រឹក និង ល្ងាច ។



**រូបភាព ២១ : ស៊ុមដាក់ចំណីត្រី (ចកបាយទា ស្លែ ត្រកួន)**

ចំណីបន្ថែមដូចជា សារាយ ត្រកួន ចកពងទឹក ចកបាយទា អង្កាដី កន្ទំថេត ពោត ដំឡូងជ្វា កណ្ដៀរ អង្រ្កង ដង្កូវ ជន្លេន កាកសំណល់ផ្ទះបាយ ។ល។ ការបន្ថែមជីរុក្ខជាតិ និងជីលាមសត្វ ១ - ២ ដង ក្នុង ១ ខែស្មើនឹង ៣០ - ៤០ ភាគរយ នៃបរិមាណជីរៀបចំស្រះដំបូង (អាស្រ័យនឹងគុណភាពទឹកក្នុងស្រះ) ។

## ៨. ចិញ្ចឹមត្រីក្នុងស្រែ (ត្រី ~ ស្រូវ)

ដើម្បីបង្កើនទិន្នផលត្រីខ្ពស់ និងកាត់បន្ថយការចំណាយចំណី គេពង្រីកការជីកស្រះជាប់ជាមួយប្រឡាយទៅនឹងស្រែ ពីព្រោះគេអាចស្តុកត្រីបានច្រើនក្នុងស្រែ និងទទួលផលទាំងត្រីផង និងស្រូវផង ។



**រូបភាព ២២ : ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយភ្ជាប់ជាមួយស្រែ**

ដើម្បីជៀសវាងការបាត់បង់កូនត្រី (សត្វស៊ី និងត្រីកាចស៊ី) យើងត្រូវបំប៉នកូនត្រីក្នុងស្រះ ឬ ហាប៉ា អោយត្រីធំបន្តិច (ប្រវែងដងខ្លួនពី ៨ - ១០ ហ៊ុន) ទើបលែងត្រីចូលទៅក្នុងប្រឡាយស្រែ ។ ចំនួនកូនត្រីលែង ២ ក្បាល ក្នុង ១ ម៉ែត្រការ៉េនៃផ្ទៃស្រែ ។

### សារៈប្រយោជន៍ចិញ្ចឹមត្រីក្នុងស្រែ

- ត្រីស៊ីសត្វល្អិត១ដែលបំផ្លាញស្រូវដូចជា : ដង្កូវ កណ្តូប ពពួកសត្វល្អិត១ ផ្កានិងគ្រាប់ស្រូវជ្រុះ
- អាចម៍ត្រីក៏ជាជីជួយដល់ដំណាំស្រូវបានល្អ
- ត្រីត្បុលស្រទាប់ដី ធ្វើអោយដីធូរ ទឹកមានខ្យល់ចូល ឫសស្រូវស្រូបខ្យល់ពីបរិយាកាសបានល្អ
- ចំណេញចំណី (ផ្តល់ចំណីតិចតួច) និងផ្ទៃរស់នៅ (ទីធ្លា) ទូលាយ ។ល ។



រូបភាព ២៣ ៖ ត្រីស៊ីរុក្ខជាតិ និងសត្វល្អិតក្នុងផុស (ត្រីស៊ីចំណីតាមស្រទាប់ផ្ទៃទឹក)



រូបភាព ២៤ ៖ ស្រះចិញ្ចឹមត្រី

## ៩. ការគ្រប់គ្រង និងថែទាំត្រី

ការចិញ្ចឹមត្រី យើងត្រូវចាប់អារម្មណ៍ទៅលើបញ្ហាមួយចំនួន ដើម្បីធានាបានទិន្នផលខ្ពស់៖

### ក. ដាក់ជីបន្ថែម

បើទឹកមានពណ៌បៃតងចាស់ត្រូវបន្ថយ ឬ ផ្អាកការដាក់ជី។ បើទឹកថ្លាត្រូវបង្កើនការដាក់ជីទៅតាមការជាក់ស្តែងនៃពណ៌ទឹកស្រះ។

### ខ. កំណត់ទីកន្លែងផ្តល់ចំណី

អោយស៊ីទៀងទាត់ និងទៀងពេល ដើម្បីអោយត្រីចាំពេល និងចាំកន្លែង មិនបាត់បង់ចំណី។

### គ. រាំងស្បៃមុង

ពេលបន្ថែមទឹកចូលស្រះត្រូវការពារត្រីស្រែចូល តាមរយៈការដាក់ស្បៃមុង។



**រូបភាព ២៥ ៖ បន្ថែមទឹកចូលស្រះត្រោះដោយស្បៃមុងកុំអោយត្រីស្រែចូល**

### ឃ. ការផ្តល់ចំណីបន្ថែម

ចំណីកែច្នៃត្រូវចំអិន (កន្ទក់ ចុងអង្ករ ពោត ម្សៅស្លឹកគ លាយជាមួយកាកសំណល់ផ្ទះបាយ)។ ចំណែកបន្លែស្រស់ (ត្រកួន ដើមចេក ស្លឹកកន្ទំថេត ស្លឹកអង្គាដី ស្ពៃ ស្លឹកដំឡូងជ្វា) ហាន់ និងបុកអោយល្អិត។ ចំពោះ សារាយ ចកបាយទា ចកពងទឹក ត្រូវធ្វើស៊ុម ។ ចំពោះកណ្តៀររែងយកដីចេញ។

### ង. រុក្ខជាតិដុះក្នុងស្រះ

សំអាត ឬ ដកចេញពីស្រះ ដូចជា រំចង់ ព្រលិត កំប្លោក ស្មៅ ។ល។ វាងាប់រលួយធ្វើអោយត្រីពុល ។



**រូបភាព ២៦ : សំអាតរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រី**

### ច. រក្សាជំរៅទឹក

រក្សាទឹកប្រឡាយក្នុងស្រែកុំអោយរាក់ពេក ធ្វើអោយទឹកក្តៅត្រីងាប់ ។

### ឆ. ត្រីពុល ឬ ត្រីងើបចំណែតខ្លួនមកលើផ្ទៃទឹកច្រើន (បរិស្ថានក្នុងស្រះមិនសមស្រប)

ក្បៀរ ឬ អូសបង្វិកត្រី ១ ខែម្តង ដើម្បីបំបែកនូវសារធាតុនៅបាតស្រះ បង្កើនខ្យល់ក្នុងទឹកស្រះ និងធ្វើអោយត្រីផ្លាស់ប្តូរទីកន្លែងក្នុងស្រះ។ បើសិនត្រីពុល (ត្រីងើបក្បាលឡើងលើផ្ទៃទឹក) បន្ថយការដាក់ជីកំប៉ុស្ត ឬ លាកមសត្វ ផ្អាកការដាក់ចំណី ១ ឬ ២ ថ្ងៃ និងផ្លាស់ប្តូរទឹកចាស់ចេញ ឬ ធ្វើអោយមានចរន្តទឹកក្នុងស្រះ។

### ជ. ដាក់ចង្កៀងលើផ្ទៃស្រះ ឬ ប្រឡាយ

ទាក់ទាញកូនសត្វមករោម វាធ្លាក់ជាចំណីត្រីស៊ី ។

### ឈ. ការពារពពួកស៊ីកូនត្រី

បើមានលទ្ធភាព រាំងព្រួល ឬ រាំងស្បៃមុង ការពារត្រីផ្ទក់ ពស់ អន្ទង់។ ពេលត្រីកាចចូលត្រូវចាប់ចេញ (ប្រើអួន សន្ទូច ឬ ដាក់បង្កៃ) ការពារបក្សីមកស៊ីត្រី និងលើកភ្លឺស្រះអោយបានខ្ពស់ និងមាំ។



រូបភាព ២៧ : ពពួកសត្វស៊ីកូនត្រី



រូបភាព ២៨ : ដាក់ចង្កៀងលើផ្ទៃស្រះទាក់ទាញសត្វល្អិត

### ៧. ទន្រ្ទានខែត្រ

ទន្រ្ទានខែត្រចងជាបាច់ភ្ជាប់នឹងបង្គោលដោតក្នុងស្រះចិញ្ចឹមត្រី។ ទន្រ្ទានខែត្រចងជាបាច់ដាក់ពន្លិចក្នុងទឹកជ្រៅ ១ - ៣ តឹក ពីផ្ទៃទឹក ដើម្បីអោយទទួលកំដៅថ្ងៃ វានឹងឆាប់រលួយក្លាយជាចំណីត្រី ។




រូបភាព ២៩ : ចងទន្រ្ទានខែត្រជាដុំដាក់ពន្លិចក្នុងទឹកស្រះចិញ្ចឹមត្រី (ជាចំណីត្រី)

## ១០. ការប្រមូលផលត្រី

▶ ការប្រមូលផលត្រីភាគច្រើនចាប់ពីចុងរដូវវស្សា ពីព្រោះទឹកស្រះ ឬ ស្រែរីង។ ដូចនេះ ដើម្បីបានប្រមូលផលត្រីចិញ្ចឹមផង និង ត្រីស្រែផង។ នៅចុងរដូវវស្សា គេបើករង្វះទឹកមកចូលស្រះពី ២ - ៣ ច្រក ដើម្បីអោយត្រីស្រែចូលមកនៅ។ ក្រោយពេលប្រមូលផលរួច គេរៀបចំស្តារ ឬ ជួសជុលទំនប់ស្រះ ប្រឡាយអោយល្អឡើងវិញ។

▶ គេអាចប្រមូលផលត្រីដោយចាប់រំលោះត្រីជាបណ្តើរ ដើម្បីអោយផ្ទៃទូលាយត្រីនឹងឆាប់ធំ ។

## ១១. ការពារ និងព្យាបាលជំងឺត្រី

### ក. ជំងឺរលាក

ស្នាមរលាក និងដំបៅនៅលើស្បែក ស្រកា រន្ធច្រមុះ ព្រុយខ្នង ព្រុយកន្ទុយត្រី ដូចជា ឆ្អិន អណ្តែង ផ្ទក់ កាបសាមញ្ញ។ ខ្លួនត្រីមានជាតិរំអិលពណ៌ប្រផេះក្លិនស្អុយ ត្រីរមាស់ហែលគ្មានទិសដៅ។

- <u>ការពារ:</u> រក្សាមជ្ឈដ្ឋានទឹកអោយស្អាតជានិច្ច និងចិញ្ចឹមនូវដង់ស៊ីតេ (បរិមាណត្រី)សមស្រប
- <u>ព្យាបាល:</u> ប្រើអំបិល (១ - ២ គីឡូក្រាម លាយជាមួយទឹក ៣០ លីត្រ) ឬ ប្រើកំបោរស ១ គីឡូក្រាម លាយជាមួយទឹក ៣០ លីត្រ បាចជុំវិញមាត់ស្រះ រយះពេលពី ៤ - ៥ ថ្ងៃ (១ ដង/ថ្ងៃ) ។

**ខ. ពពួកបរាសិត**

គោងជាប់នៅលើស្បែក ស្រកា ស្រកី ភ្នែក ព្រុយត្រី។ ត្រីហែលគ្មានទិសដៅ មិនស៊ីចំណី ខ្លួនត្រីហើម ក្រហម និងជញ្ជក់ឈាមត្រីធ្វើអោយត្រីខ្សោយ និងងាប់ ។

- <u>ការពារ:</u> សំអាតស្រះអោយស្អាតមុនពេលដាក់ត្រីចិញ្ចឹម និង រក្សាទឹកអោយស្អាតជានិច្ច។
- <u>ព្យាបាល:</u> ចិញ្ច្រាំស្លឹកស្ដៅដាក់ក្នុងថង់ (០,៥ គីឡូក្រាម ស្លឹកស្ដៅក្នុង ១ ថង់)។ ស្រះ ១០០ ម៉ែត្រការេ ដាក់ពី ៤ - ៦ ថង់។ ថង់ដាក់ស្លឹកស្ដៅដាក់ពន្លិចនៅបាតស្រះ ហើយថង់នោះត្រូវចោះអោយមានរន្ធតូចៗ។

## ១២. បទពិសោធន៍សំខាន់ៗ របស់កសិករក្នុងការចិញ្ចឹមត្រី

### ១២.១ បទពិសោធន៍កសិករ នាក់ ហ៊ឹម

បងប្រុស នាក់ ហ៊ឹម ជាកសិករនៅភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។ គាត់មានបទពិសោធន៍ក្នុងការចិញ្ចឹមត្រីតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ៣០០ ម៉ែត្រការេ និងជំរៅ ១,៧ ម៉ែត្រ។ គាត់ទទួលផលត្រីបានជាង ១០០ គីឡូក្រាម (កូនត្រីដាក់ចំនួន ១២០០ ក្បាល)។ បទពិសោធន៍ដែលទទួលបានផលខ្ពស់របស់គាត់បង្ហាញជូនដូចខាងក្រោម:

**ក. ការរៀបចំស្រះ**

- ស្ការភក់បាតស្រះ និង មានជីកប្រព័ន្ធប្រឡាយអោយត្រីចេញចូលពីស្រះមកស្រែ
- បាចកំបោរស ១០ គីឡូក្រាម ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់លាមកគោ ៥០ គីឡូក្រាម
- ទន្រ្ទានខែត្រ ៥០ គីឡូក្រាម ។

**គ. ចំនួនកូនត្រីដាក់ចិញ្ចឹម**

- មានប្រភេទត្រី ឆ្ពិន ប្រា កាបស កន្ធរ ទីឡាព្យា
- សរុបកូនត្រី ១២០០ ក្បាល ( ១ ម៉ែត្រការេផ្ទៃស្រះ លែងកូនត្រី ៤ ក្បាល)
- ប្រវែងកូនត្រី ៣ សង្ទីម៉ែត្រ (ត្រាំថង់កូនត្រី ១៥ នាទី មុននឹងលែងកូនត្រីចេញពីថង់ចូលស្រះ) ។

**ឃ. ការផ្តល់ចំណី**

- ប្រភេទចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ
- ផ្តល់ចំណី ៥ គីឡូក្រាម ក្នុង ១ ថ្ងៃ ចែកជា ២ ពេល (ព្រឹក និងល្ងាច) ។

**ង. ការគ្រប់គ្រង និងថែទាំ**

- ការពារមនុស្សឆក់
- ការពារសត្វមកបំផ្លាញពេលកូនត្រីនៅតូច
- ផ្តល់ចំណីរៀងរាល់ថ្ងៃ
- សំអាតស្មៅជុំវិញស្រះ និងស្លឹកឈើជ្រុះចូល ។

**ច. រយៈពេលចិញ្ចឹម :** ១១ ខែ

**ឆ. យោបល់បន្ថែម**

- ត្រូវប្តូរទឹកចាស់ក្នុងស្រះចេញ ៥០ ភាគរយ
- ត្រូវបង្ហឹកត្រីក្នុងស្រះ ១ ដង ក្នុង ១ ខែ។

## ១២.២ បទពិសោធន៍កសិករ កែវ ប៊ុន

បងប្រុស កែវ ប៊ុន ជាកសិកររស់នៅភូមិទីប៉ាត់ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់មានបទពិសោធន៍ល្អៗច្រើនក្នុងការចិញ្ចឹមត្រី ។ ស្រះរបស់គាត់មានទំហំ ៣០០ ម៉ែត្រការេ និងជំរៅ ២,៥ ម៉ែត្រ។ គាត់ទទួលផលត្រីបានជាង ១០០ គីឡូក្រាម (កូនត្រីដាក់ចំនួន ១៣០០ ក្បាល។ បទពិសោធន៍ ដែលទទួលផលខ្ពស់របស់គាត់បង្ហាញជូនដូចខាងក្រោម:

**ក. ការរៀបចំស្រះ**

- ស្តារភក់បាតស្រះ និង មានជីកប្រព័ន្ធប្រឡាយអោយត្រីចេញចូលពីស្រះមកស្រែ
- បាចកំបោរស ៥ គីឡូក្រាម និងហាលពន្លឺថ្ងៃបាតស្រះចំនួន ៣ ថ្ងៃ ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់លាមកគោ ២០ គីឡូក្រាម
- ទន្រ្ទានខែត្រ ១៥ គីឡូក្រាម ។

**គ. ចំនួនកូនត្រីដាក់ចិញ្ចឹម**

- មានប្រភេទត្រីឆ្ពិន កាបស កាបឥណ្ឌា កន្ធរ
- សរុបកូនត្រី ១៣០០ ក្បាល ( ១ ម៉ែត្រការេផ្ទៃស្រះ លែងកូនត្រីចំនួន ៤ ក្បាល)
- ប្រវែងកូនត្រី ៣ សង្ទីម៉ែត្រ ( ត្រាំថង់កូនត្រី ១៥ នាទី មុននឹងលែងកូនត្រីចេញពីថង់ចូលស្រះ) ។

**ឃ. ការផ្តល់ចំណី**

- ប្រភេទចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ និងត្រកួន
- អោយស៊ី ៣ គីឡូក្រាម ក្នុង ១ ថ្ងៃ ចែកជា ២ ពេល ( ព្រឹក និងល្ងាច) ។

**ង. ការគ្រប់គ្រង និងថែទាំ**

- ការពារសត្វមកបំផ្លាញពេលកូនត្រីនៅតូច
- ផ្តល់ចំណីរៀងរាល់ថ្ងៃ
- សំអាតស្មៅជុំវិញស្រះ និងស្លឹកឈើ
- ទឹកស្រះមានប្លង់តុង ( ទឹកពណ៌បៃតងខ្ចី) ។

**ច. រយៈពេលចិញ្ចឹមៈ** ៧ ខែ

**ឆ. បោចលំបាក**

- ប្តូរទឹកចាស់ក្នុងស្រះចេញ ៥០ ភាគរយ
- បង្ហូរត្រីក្នុងស្រះ ១ ដង ក្នុង ១ ខែ ។

## ១២.៣ បទពិសោធន៍កសិករ ចាន់ សុធា

បងប្រុស ចាន់ សុធា ជាកសិកររស់នៅភូមិទីប៉ាត់ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់មានបទពិសោធន៍ក្នុងការចិញ្ចឹមត្រីតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ៣២០ ម៉ែត្រការេ និងជំរៅ ២.៥ ម៉ែត្រ។ គាត់ទទួលផលត្រីបានជាង ៥៥ គីឡូក្រាម ក្រោយពីចាប់ហូប (កូនត្រីដាក់ចំនួន ១០០០ ក្បាល)។ បទពិសោធន៍ដែលទទួលបានផលខ្ពស់របស់គាត់បង្ហាញជូនដូចខាងក្រោមៈ

**ក. ការរៀបចំស្រះ**

- ស្តារភក់បាតស្រះ និង មានជីកប្រព័ន្ធប្រឡាយអោយត្រីចេញចូលពីស្រះមកស្រែ
- បាចកំបោរស ១០ គីឡូក្រាម និងហាលពន្លឺថ្ងៃបាតស្រះ ចំនួន ៣ ថ្ងៃ ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់លាមកគោ ១០០ គីឡូក្រាម
- ទន្រ្ទានខែត្រ ៤៥ គីឡូក្រាម ។

**គ. ចំនួនកូនត្រីដាក់ចិញ្ចឹម**

- មានប្រភេទត្រីឆ្ពិន កាបស កាបឥណ្ឌា កន្ធរ និងកាបសាមញ្ញ
- សរុបកូនត្រី ១០០០ ក្បាល ( ១ ម៉ែត្រការេផ្ទៃស្រះ លែងកូនត្រីចំនួន ៣ ក្បាល)
- ប្រវែងកូនត្រី ៣ សង្ទីម៉ែត្រ ( ត្រាំថង់កូនត្រី ១៥ នាទី មុននឹងលែងកូនត្រីចេញពីថង់ចូលស្រះ) ។

**ឃ. ការផ្តល់ចំណី**

- ប្រភេទចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ
- អោយស៊ី ១ គីឡូក្រាម ក្នុង ១ ថ្ងៃ ចែកជា ២ ពេល ( ព្រឹក និងល្ងាច)
- មានចំណីបន្ថែម ដូចជា ចកបាយទា ត្រកួន ។

**ង. ការគ្រប់គ្រង និងថែទាំ**

- ការពារសត្វមកបំផ្លាញពេលកូនត្រីនៅតូច
- ផ្តល់ចំណីរៀងរាល់ថ្ងៃ
- សំអាតស្មៅជុំវិញស្រះ និងស្លឹកឈើ
- ទឹកស្រះមានប្លង់តុង ( ទឹកពណ៌បៃតងខ្ចី) ហើយត្រីមិនពុល ។

**ច. រយៈពេលចិញ្ចឹមៈ ៧ ខែ**

**ឆ. របៀបលប់បន្ថែម**

- ប្តូរទឹកចាស់ក្នុងស្រះចេញ ៥0 ភាគរយ
- បង្វឹកត្រីក្នុងស្រះ ១ដង ក្នុង ១ ខែ

## ១៣. ការសរុបនូវចំណុចសំខាន់ៗ និង សំណូមពរ

សរុបមកដើម្បីអោយយើងចិញ្ចឹមត្រីបានផលខ្ពស់ គួរអនុវត្តន៍តាមចំណុចសំខាន់ដូចខាងក្រោម :

- ☞ រៀបចំសំអាតស្រះដូចជា បាចកំបោរស ហាលពន្លឺថ្ងៃ ដាក់ជីទ្រាប់បាតស្រះ លើកទំនប់
- ☞ បង្កើតចំណីធម្មជាតិ ( ទឹកពណ៌បៃតង ) មុនពេលដាក់ត្រីចិញ្ចឹម
- ☞ មុនពេលលែងត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រះរយៈពេល ១៥នាទី និងដឹកជញ្ជូននៅពេលព្រឹក និង ល្ងាច
- ☞ ការពារត្រីកាចកុំអោយចូលស្រះ ( ត្រីផ្ទក់ )
- ☞ ផ្តល់ចំណីអោយស៊ី ក្រោយពីលែងកូនត្រីចូលស្រះបានពី ២ - ៣ ថ្ងៃ
- ☞ កូនត្រីចិញ្ចឹម មានប្រវែងដងខ្លួនពី ៤ - ៦ ហ៊ុន ឬ ៨ ហ៊ុន
- ☞ ចំនួនកូនត្រីចិញ្ចឹម ៣ ក្បាល ក្នុង ១ ម៉ែត្រការេនៃផ្ទៃស្រះ
- ☞ រក្សាជំរៅទឹកស្រះរាក់បំផុត គឺ ១,៥ ម៉ែត្រ និង ជ្រៅបំផុត ៣ ម៉ែត្រ
- ☞ ផ្តល់ចំណីអោយស៊ីទៀងពេល និងកំណត់ទីកន្លែងផ្តល់ចំណី

☞ ស្រះទទួលពន្លឺថ្ងៃបានគ្រប់គ្រាន់ គ្មានដើមឈើធំៗ នៅក្បែរស្រះចិញ្ចឹមត្រី

☞ ប្តូរទឹកស្រះចិញ្ចឹមត្រីពី ៣០ - ៤០ ភាគរយ នៃទឹកក្នុងស្រះ ( ពេលទឹកគ្មានគុណភាព)

☞ សំអាតស្មៅ ឬ រុក្ខជាតិដុះក្នុងស្រះ និងជុំវិញមាត់ស្រះចិញ្ចឹមត្រី

☞ ដើរត្រួតពិនិត្យតាមមាត់ស្រះពេលព្រឹកព្រលឹម ( អង្កេតសកម្មភាពត្រី ឬ ត្រីពុល) ។

ដូចគ្នាដែរ ដើម្បីចិញ្ចឹមត្រីអោយបានផលខ្ពស់ យើងត្រូវជៀសវាងនូវចំនុចមួយចំនួនដូចខាងក្រោមៈ

☞ កុំលែងកូនត្រីពេលកំពុងភ្លៀង ( ពីព្រោះទឹកភ្លៀងមានជាតិអាស៊ីតធ្វើអោយត្រីងាប់ឬពុល )

☞ ពេលត្រីពុលត្រូវផ្អាកការដាក់ជី ឬ ផ្តល់ចំណីពី ១ - ២ ថ្ងៃ

☞ កុំបើករង្វះមាត់ស្រះមុនពេលដាក់កូនត្រីចិញ្ចឹម ( ត្រីកាចចូលស៊ី)

☞ ជៀសវាងការប្រើថ្នាំពុល ជីគីមី និង ឧបករណ៍ឆក់ក្នុងការចាប់ត្រី

☞ ជៀសវាងកៀរត្រីពេលមេឃក្តៅ ( ទឹកក្នុងស្រះក្តៅធ្វើអោយត្រីរលាកស្រកា ឬ ស្រកីត្រី)

☞ ជៀសវាងកៀរត្រីនៅពេលមេឃក្តៅ ឬ ក្រោយពេលដាក់ចំណីភ្លាម ។

យើងត្រូវកត់ត្រារៀងរាល់ការចំណាយរហូតដល់ពេលប្រមូលផលត្រីដើម្បីទូទាត់ ការចំណាយ និង ចំណូលសរុប ក្នុងការចិញ្ចឹមត្រី

តារាង ៣ កត់ត្រាការប្រមូលផលត្រី

| ចំនួនស្រះ | ផ្ទៃស្រះ (ម<br>២<br>) | បរិមាណត្រីដាក់ចិញ្ចឹម | | ទំងន់ត្រីប្រមូលផល | | តំលៃត្រី | |
|---|---|---|---|---|---|---|---|
| | | ប្រភេទត្រី | ចំនួនក្បាល | ក្បាល/គ.ក្រ | ទំងន់សរុប ( គ.ក្រ ) | តំលៃរាយ/គ.ក្រ | តំលៃសរុប |
| | | | | | | | |
| | | | | | | | |

តារាង ៤ ការកត់ត្រាការចំណាយលើមុខផ្សេងៗ

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តំលៃរាយ (រៀល) | តំលៃសរុប (រៀល) |
|---|---|---|---|---|---|
| ១ | កូនត្រីពូជ | ក្បាល | ? | ? | ? |
| ២ | ចំណី | គ.ក្រ | ? | ? | ? |
| ៣ | ជី (លាមកសត្វ និង រុក្ខជាតិ) | គ.ក្រ | ? | ? | ? |
| ៤ | កំបោរស | គ.ក្រ | ? | ? | ? |
| ៥ | ចំណាយផ្សេងៗ | | ? | ? | ? |
| សរុប | | | | | |

# ឯកសារយោង


១. Carlos William W. Azucena, Ma. Stella S. Oliver, Berndette P. Joven, Siobhan O'Malley and Mayla Henrnandez Viraly. (2001). Utilizing Different Aquatic Resource for Livelihoods Asia : A Resource Book. Page: 63-74.
(ការប្រើប្រាស់ប្រភពធនធានវារីជាតិផ្សេងៗគ្នាក្នុងការចិញ្ចឹមជីវិតនៅអាស៊ី) ។

២. Dela Cruz, C.R., Lightfoot, C., Colsta-PIerce, B.a., Carangal, V.R and Bimbao, M.P .(1992). Rice- Fish Research and Development in Asia. page: 77 - 89. ( ការសិក្សាស្រាវជ្រាវត្រី-ស្រូវ និងការអភិវឌ្ឍន៍ នៅអាស៊ី) ។

៣. Edards P. and Kaewpaittoon K, (1984). "Fish Culture for Small -Scale Farmers" . Asian Institute of Technology, Bangkok. (ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ) ។

៤. FAO Training Series 24. (1994). Handbook on Small Scale Freshwater Fish Farming.
(សៀវភៅខ្នាតតូចៈ ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ) ។

៥. Nguyen Duy Khoat .(1999). ការណែនាំចិញ្ចឹមត្រីទឹកសាប (ភាសាវៀតណាម ) ។

៦. Woynaronvich, E. & Horvath, L. (1980). The artificial propagation of warm-water finfishes - A manual for extension. FAO Fisheries Technical Paper No.201.
(បច្ចេកទេសផលិតពូជត្រីសិប្បនិម្មិត - សំរាប់ការផ្សព្វផ្សាយ) ។

៧. រាជ សុភាព (២០០២) បច្ចេកទេសបន្សាំកូនត្រីក្នុងហាប៉ា និងក្នុងស្រះ (ឯកសារមិនបោះពុម្ពផ្សាយជាផ្លូវការ) ។

## មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/CEDAC)

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ ។ "សេដាក" ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជាមួយប្រកបដោយចីរភាព និងសមធម៌ ដែលប្រជាកសិករ និងអ្នកបរិភោគមានជីវិតរស់នៅប្រកបដោយភាពសប្បាយរីករាយ ។

សេដាក បានចាប់ដៃជាមួយកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីផ្តួចផ្តើមគំនិតអនុវត្ត និងគាំទ្រដល់គំរោង ឬសកម្មភាពដែលចូលរួមចំណែកដល់អធិបតេយ្យភាពស្បៀង និងការបង្កើនទូវគុណភាពនៃជីវិតរបស់ប្រជាកសិករ និងអ្នកបរិភោគ ដោយជាមួយគ្នានោះរក្សា និងបង្កើនទូវគុណភាពនៃធនធាន ធម្មជាតិ និងការសហការគ្នាក្នុងសង្គម ។

☞ ចងក្រង និងបោះពុម្ពផ្សាយដោយ **មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/CEDAC)**

☞ ឧបត្ថម្ភថវិកាដោយអង្គការអុកស្វាមអាមេរិក (Oxfam America)

☞ ពត៌មានផ្សេងៗ និង ការចែកចាយផ្សព្វផ្សាយ សូមទំនាក់ទំនង:

ផ្ទះលេខ ៣៩ ផ្លូវលេខ ៥២៨ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក

ប្រអប់សំបុត្រលេខ ១១១៨ រាជធានីភ្នំពេញ

ទូរស័ព្ទ: (០២៣) ៨៨០ ៩១៦ ទូរសារ: (០២៣) ៨៨៥ ១៤៦ E.mail : Cedac@camnet.com.kh


ចិញ្ច្រាំបន្លែអោយត្រីស៊ី


ដាក់ជីលាមកសត្វទ្រាប់បាតប្រឡាយ


របៀបលែងកូនត្រី


សកម្មភាពត្រីស៊ីចំណីចំរុះ


ពិនិត្យចំណី និងបរិមាណត្រី


ដុំទន្ទ្រានខែត្រចងពន្លិចដាក់ក្នុងស្រះ


សំអាតរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រី


បញ្ចូលទឹកក្នុងស្រះច្រោះដោយស្បៃមុង